ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

## សេចក្តីប្រកាសព័ត៌មាន
## ទស្សនកិច្ចសិក្សា និងចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងការរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ការិយាល័យស៊ើបអង្កេតការប្រឆាំងការសម្អាតប្រាក់នៃធនាគារកណ្តាលឡាវនៃសាធារណរដ្ឋប្រជាមានិតឡាវ នៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិនៃកម្ពុជា

ថ្ងៃទី២៦-២៧ ខែធ្នូ ឆ្នាំ២០១៦

នាព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) នៃធនាគារជាតិនៃកម្ពុជា បានរៀបចំទទួលទស្សនកិច្ចសិក្សារបស់គណៈប្រតិភូរបស់ការិយាល័យស៊ើបអង្កេតការប្រឆាំងការសម្អាតប្រាក់នៃធនាគារកណ្តាលឡាវ ចំនួន ៥ រូប និងការិយាល័យរដ្ឋអាជ្ញាជាន់ខ្ពស់នៃសាធារណរដ្ឋប្រជាមានិតឡាវ ចំនួន ១ រូប ក្នុងគោលបំណងចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងការរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ទស្សនកិច្ចសិក្សានេះ មានរយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី២៦ ដល់ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ដែលមិនត្រឹមតែផ្តល់ឱកាសឲ្យភាគីឡាវ សិក្សាបទពិសោធន៍ការងារទាក់ទងនឹងការវាយតម្លៃហានិភ័យថ្នាក់ជាតិរបស់កម្ពុជាស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលភាគីកម្ពុជាទើបបានបញ្ចប់ទៅនាពេលថ្មីៗកន្លងទៅនេះប៉ុណ្ណោះទេ ព្រមទាំងផ្តល់ឱកាសដល់ភាគីទាំងពីរ អាចសិក្សាពីរបបការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរវាងគ្នាទៅវិញទៅមក ដើម្បីឲ្យភាគីឡាវត្រៀមលក្ខណៈជាមុនឲ្យបានសមស្របមុននឹងទទួលរងការវាយតម្លៃអញ្ញមញ្ញរបស់ខ្លួននៅពេលខាងមុខ ។

ទន្ទឹមនឹងនេះ ទស្សនកិច្ចសិក្សានេះ ក៏ជាការបង្ហាញពីការពង្រឹងចំណងមិត្តភាពនិងឆន្ទៈក្នុងកិច្ចសហប្រតិបត្តិការទាំងក្នុងឆាកអន្តរជាតិ និងក្នុងតំបន់រវាងភាគីទាំងពីរ ក្រោយពីការចុះអនុស្សរណៈយោគយល់ កាលពីខែមិនា ឆ្នាំ២០១៥ កន្លងមក ។ ទស្សកិច្ចសិក្សា និងចែករំលែកបទពិសោធន៍រវាងភាគីឡាវ និងកម្ពុជា ក្នុងរយៈពេលពីរថ្ងៃនេះ បានប្រព្រឹត្តទៅក្រោមបរិយាកាសដ៏សោមនស្សរីករាយក្រៃលែង ។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧